**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរទន្លេសាប**

គណៈកម្មាធិការលទ្ធកម្ម

លេខ : ......១០៤......អទស.សជណ

# សេចក្តីជូនដំណឹង

## ស្តីពី

## ការអញ្ជើញចូលរួមដេញថ្លៃការងារផ្គត់ផ្គង់ប្រេងឥន្ធនៈឆមាសទី ២ ឆ្នាំ ២០១៨

អាជ្ញាធរទន្លេសាប (ក្រសួងធនធានទឹក និងឧតុនិយម) សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា ៖ អាជ្ញាធរទន្លេសាបនឹងដាក់ឱ្យដេញថ្លៃជាសាធារណៈដើម្បីផ្គត់ផ្គង់ប្រេងឥន្ធនៈឆមាសទី ២ ឆ្នាំ ២០១៨ របស់អាជ្ញាធរទន្លេសាប ។

អាជ្ញាធរទន្លេសាប បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃនិងមានដាក់លក់នៅអង្គភាពលទ្ធកម្មអាជ្ញាធរទន្លេសាប (ក្រសួងធនធានទឹក និងឧតុនិយម) ដែលមានអាសយដ្ឋាន អគារលេខ៥៧៦ ផ្លូវជាតិលេខ ២ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០១៨ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទង០២៣ ៧២៧ ៤៥៤,០៨០ ៥៥៥ ៥៨០) ។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោង៩:០០នាទីព្រឹក ថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ ២០១៨ ។

ការបើកសំណើដេញថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើវេលាម៉ោង៩:០០ នាទីព្រឹក ថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ ២០១៨ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មដើម្បីទិញឯកសារដេញថ្លៃនិងសាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ។

ថ្ងៃ សុក្រ ១០កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ២០១៨

ជ. **ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ហ៊ែល_តូនី**

ចម្លងជូន ៖

-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ